ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚***៛

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

លេខ..១២៤៤..ដនស.ក/..

ភ្នំពេញ . ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤

នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

ជំរាបមក

ឯកឧត្តម អភិបាលគ្រប់ខេត្ត-ក្រុង

<u>កម្មវត្ថុ</u> : ការទប់ស្កាត់ មិនឱ្យមានការបង្កើតក្រុមវាស់វែងជាឯកជន ក្រៅពីរដ្ឋបាលសុរិយោដី

<u>យោង</u> : មាត្រា ២២៩ ( ភារកិច្ចទី ៣ ) និង មាត្រា ២៣៥ ( ៦-២ ) នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

សេចក្តីដូចបានចែងក្នុងកម្មវត្ថុនិងយោងខាងលើខ្ញុំសូមជំរាបដល់ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុង មេត្តាជ្រាបថា កន្លងមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តែងតែលេចឮនូវបាតុភាពទំនាស់ស្តែងចេញពីការបោះបង្គោលព្រំដីរលោកបំពានចូលគ្នាទៅវិញទៅមក ។មិនតែប៉ុណ្ណោះសោតទំនាស់ក្តីក្តាំដែលកើតមានជាហូរហែរនោះ ភាគច្រើនច្រើនតែបណ្តាលមកពីការវាស់វែងឯកជន ដោយខុសពីលក្ខណៈបច្ចេកទេស និង ស្តង់ដារទាក់ទងទៅនឹងឯកសារ ។

បន្ថែមពីលើផលវិបាកខាងលើក្រុមវាស់វែងឯកជនដែលអាជ្ញាធរមូលដ្ឋានបង្កើតដោយខ្លួនឯងនោះជាកត្តាមួយនាំឱ្យមានការភាន់ច្រឡំនិងនាំឱ្យកើតមានភាពអានាធិបតេយ្យដូចជាការចូលទៅវាស់វែងលើដីជាសម្បត្តិរដ្ឋឬឯកជនយកទៅលក់ឱ្យឈ្មួញឬលក់ឱ្យបុគ្គលឯកជនដោយតំលៃថោក១ដើម្បីបន្លំបោកប្រាស់ ។

ដោយយោងលើស្មារតីខាងលើនេះខ្ញុំសូមធ្វើសំណូមពរដល់ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុង មេត្តាជួយទប់ស្កាត់យ៉ាងណាដើម្បីជៀសវាងនូវភាពអនាធិបតេយ្យក្នុងការចូលទន្ទ្រានកាន់កាប់ដីធ្លីដោយខុសច្បាប់និងដើម្បីកាត់បន្ថយនូវទំនាស់ដីធ្លីមួយចំណែកទប់ស្កាត់និងលុបបំបាត់ចោលជាស្ថាពរនូវក្រុមវាស់វែងដែលអាជ្ញាធរមូលដ្ឋានបានបង្កើតដោយខ្លួនឯងជាបន្ទាន់ព្រោះថាអំពើទាំងនេះជាអំពើខុសច្បាប់ដោយហេតុថានៅកម្ពុជាយើងពុំទាន់មានច្បាប់ឱ្យបង្កើតក្រុមវេខាគណិតស៊ីវិល (Cabinet du Géomètre civil ) នៅឡើយទេ ។

សូម ឯកឧត្តម អភិបាលគ្រប់ខេត្ត-ក្រុង ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

នេសរដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

<u>ចម្លងជូន</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ទីស្តីការក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- មន្ទីរ ដនសស គ្រប់ខេត្ត-ក្រុង
  "ដើម្បីសហការអនុវត្ត"
- ទុកឯកសារ